**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦២ ស.សរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់ នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ កម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០២០ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩០ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពគ្រប់គ្រងដឹកនាំ នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា-ថៃ ដែលមានសមាសភាព ដូចតទៅ ៖

www.pheakdeylaw.com

១-ឯកឧត្តម សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា ប្រធាន

២- ឯកឧត្តម បណ្ឌិត ហេង វង្សប៊ុនឆាត អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ជា ឧត្តមទីប្រឹក្សា

៣- ឯកឧត្តម ហូ វិចិត្រ អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៤- ឯកឧត្តម វ៉ា គីម ហុង ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ជា អនុប្រធាន

៥- ឯកឧត្តម តែ ដួង តារា អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា ជា អនុប្រធាន

៦- តំណាងឧត្តមនាវីឯក អ៊ុង សំខាន់. មេបញ្ជាការកងទ័ពជើងទឹក ជា សមាជិក

៧- លោក ឡេប សារីរិសិដ្ឋ ជំនួយការផ្ទាល់ឯកឧត្តមទេសរដ្ឋមន្ត្រី ជាសមាជិក

៨- លោក ហួន សាវ៉ាង អគ្គនាយករងនៃក្រសួងរៀបចំដែនដី-នគរូបនីយកម្ម និង សំណង់ ជាសមាជិក

៩- លោក ឆាយ សុខន ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជា សមាជិក

១០-លោក ឃួន សុគន្ធា អនុប្រធានផ្នែកទទួលបន្ទុកកិច្ចការច្បាប់ និង ចរចា ជាសមាជិក

១១-លោក ញឹក សុមេធ មន្ត្រីនៃផ្នែកទទួលបន្ទុកកិច្ចការច្បាប់ និង ចរចា ជាសមាជិក

**ប្រការ ២** : គណៈកម្មាធិការបច្ចេកទេសចំរុះ ទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាតនៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នា នៃខ្ពង់រាបបាតសមុទ្រ កម្ពុជា-ថៃ មានភារកិច្ចដូចខាងក្រោម ៖

(ក) ចរចារៀបចំសន្ធិសញ្ញា និង គ្រប់ប្រព័ន្ធច្បាប់គ្រប់គ្រង-បទបញ្ញត្តិ-គោលការណ៍-បទដ្ឋាន ទាំងអស់ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍន៍រួមគ្នានៃធនធានប្រេងកាតរាប់បញ្ចូលទាំងមូលដ្ឋានគ្រឹះដែលមានផលប្រយោជន៍ទៅវិញទៅមក និង អាចទទួលយកបានដោយភាគីទាំងពីរ ចំពោះការបែងចែកលើការចំណាយនិងផលចំណេញ នៃការធ្វើអាជីវកម្មលើធនធានអ៊ីដ្រូការប៊ួរ ដែលឋិតនៅក្នុងតំបន់ នៃការអភិវឌ្ឍន៍រួមគ្នា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(ខ) ចរចារៀបចំសន្ធិសញ្ញាលើការកំណត់បែងចែកព្រំដែនសមុទ្រផ្ទៃក្នុង. ខ្ពង់រាបបាតសមុទ្រ និង តំបន់ឯកសិទ្ធិសេដ្ឋកិច្ច ដែលឋិតនៅចន្លោះនៃការទាមទារអះអាងដែនសមុទ្រ បច្ចុប្បន្នរៀង១ខ្លួនរបស់ប្រទេសទាំងពីរនៅក្នុងតំបន់ដែលនឹងត្រូវបែងចែកព្រំដែនអនុលោមទៅតាមបណ្តាគោលការណ៍ទាំងឡាយដែលអាចអនុវត្តបាន នៃច្បាប់អន្តរជាតិ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

(គ) ដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះត្រូវចុះអង្កេត-ផ្ទៀងផ្ទាត់រួមគ្នាលើ និយាមការ ( កូអ័រដោណេ ) នៃកោះ. ថ្ម. ថ្មប៉ប្រះទឹក.ចំណុចមួយ១ និងអ្វី១

www.pheakdeylaw.com

ទាំងអស់ ដែលមានលក្ខណៈពិសេស និង ចរិតប្រវត្តិសាស្ត្រពាក់ព័ន្ធ ឋិតនៅក្នុងដែនដីគោក និង ដែនសមុទ្រ កម្ពុជា -ថៃ ។

**ប្រការ ៣** : គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះ ត្រូវជួបប្រជុំគ្នាអោយបានទៀងទាត់ ក្នុងទស្សនៈសំរេចអោយបាន នូវការងាររបស់ខ្លួនទាក់ទងទៅនឹងបញ្ហាទាំងអស់នេះអោយបានឆាប់រួសរាន់ ។ គណៈកម្មាធិការបច្ចេកទេសចំរុះគ្នានេះអាចបង្កើតឡើងនូវអនុគណៈកម្មាធិការដូចដែលអ្វីសមស្របទៅនឹងតំរូវការចាំបាច់ ។

**ប្រការ ៤** : គ្រប់សមាជិកនៃគណៈកម្មាធិការបច្ចេកទេសចំរុះនេះ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ហើយគណៈកម្មាធិការនេះមានសិទ្ធិអញ្ជើញអ្នកបច្ចេកទេសចូលរួមតាមការចាំបាច់ នឹងត្រូវរាយការណ៍ជូនរាជរដ្ឋាភិបាលលើលទ្ធផលនៃការងាររបស់ខ្លួន។

**ប្រការ ៥** : គណៈកម្មាធិការបច្ចេកទេសចំរុះនេះ មានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និង មានសិទ្ធិ ប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦** : សេចក្តីសំរេចលេខ ៣៨ សសរ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់, សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ - កាលប្បវត្តិ

www.pheakdeylaw.com